# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ អំពីព្រះសកម្មភាពរបស់ព្រះករុណា សម្ដេចនរោត្ដម-សីហនុចំពោះទឹកដីកម្ពុជាក្រោម ។

website : www.hoksavann.org

ថ្ងៃទី១១ មករា ២០០៦



កម្ពុជាក្រោមជាទឹកដីរបស់រាជាណាចក្រកម្ពុជា បានត្រូវបារាំងអាណានិគមប្រគល់ឲ្យព្រះចៅបាវដាយនៃប្រទេ-សវៀតណាម កាលពីថ្ងៃទី៤ មិថុនា ឆ្នាំ១៩៤៩ ។ ចំពោះការបាត់បង់ទឹកដីកម្ពុជាក្រោមនេះ ជាដំបូងយើងចង់ដឹងអំពីជំហរនិងព្រះសកម្មភាពរបស់ព្រះករុណាសម្ដេចព្រះនរោត្ដមសីហនុ អតីតព្រះមហាក្សត្រនៃប្រទេសកម្ពុជា ព្រោះការបាត់បង់នេះនៅក្នុងរាជ្យព្រះអង្គ ។ ព្រះចុតហ្មាយដែលព្រះអ-ង្គសរសេរពីប៉េកាំងចុះថ្ងៃ១៦តុលា២០០៥ សូមដកស្រង់ពាក្យខ្លះ ព្រះអង្គមានបន្ទូលថា «កើតមកជាខ្មែរ គ្មានអ្នកណាម្នាក់ដែលមិនស្រឡាញ់ជាតិ ស្រឡាញ់កម្ពុជាក្រោម និងកោះត្រល់នោះទេ» ។ ព្រះអង្គបានលើកយកព្រះញាតិរបស់ព្រះអង្គមួយអង្គ មានត្រកូលនរោត្ដមបានត្រូវសុគត ដោយធ្វើឃាតកម្មចងព្រះសុរង ដោយការឈឺចាប់មិនបានជោគជ័យអំពីការទាមទារកម្ពុជាក្រោមពីបារាំង ។ មួយព្រះអង្គទៀតព្រះនាមព្រះនរោត្ដម-សុធារសត្រូវបារាំងមិនឲ្យសោយរាជ្យ ដោយសារបារាំងដឹងការសម្ងាត់ថា បើព្រះអង្គឡើងសោយរាជ្យ ព្រះអង្គនឹងទាមទារកម្ពុជាក្រោមពីបារាំងភ្លាម ។ ព្រះអង្គមានបន្ទូលថា «ខ្ញុំបានបញ្ជូនសម្ដេចប៉ែន-នុត, សម្ដេចសឺន-សាន, ឯកឧត្ដមសម-សារី ទៅតវ៉ាជាបន្តបន្ទាប់ជាមួយបារាំង ថាខ្ញុំពុំសុខចិត្តសុខកាយ ចំពោះការផ្ទេរកម្ពុជាក្រោមទៅឲ្យវៀតណាមទេ» ។

ទាក់ទងនឹងបញ្ហាកម្ពុជាក្រោមនេះ យើងសូមដកស្រង់ឃ្លាមួយនៅក្នុងអត្ថបទដ៏វែងរបស់លោកឈាន-វ៉ម ចុះថ្ងៃ១៦ មេសា ឆ្នាំ១៩៩៩ ជាភាសាអង់គ្លេស ដែលអត្ថបទដើមជាភាសាបារាំង ដើម្បីយកមកប្រៀបធៀបគ្នាមើល អំពីព្រះបន្ទូលព្រះអ

ង្គខាងលើនេះ ។ ឃ្លានោះពោលថា មុនឡើងយន្តហោះទៅជួបលោកសឺន-សាន
នៅទីក្រុងប៉ារីសប្រទេសបារាំង លោកឈាន-វ៉ំមបានទៅព្រះបរមរាជវាំង ដើម្បីថ្វា
យបង្គំលាព្រះករុណាសម្តេចព្រះនរោត្តម-សីហនុ នៅពេលនោះព្រះករុណាបាន
មានព្រះបន្ទូលទៅគាត់ថា កិច្ចការកម្ពុជាក្រោមគឺស្ថិតនៅជិតនឹងព្រះទ័យព្រះអង្គ ។
ព្រះអង្គមានបន្ទូលថា បើការតវ៉ារបស់យើងមិនបានសំរេចជាទីពេញចិត្តបានឡើយ
។ យើងសូមសរសេរឃ្លានេះ ក្រែងការបកប្រែមានការឃ្លៀងឃ្លាត «I went to the
Royal Palace to say goodbye to the King. Here is the latter has said to me
that the <Kampuchea Krom Affaires> was close to his heart. He said that if
our claims were not satisfieds.» ។ ត្រង់ឃ្លានេះបញ្ជាក់ថា ព្រះអង្គបានឃាត់គណៈ
ប្រតិភូនៃរាជរដ្ឋាភិបាលខ្មែរ មិនឲ្យទាមទារកម្ពុជាក្រោមពីបារាំងតទៅទៀត បើដូច្នេះ
នៅមានការសង្ស័យថា តើមានអាថ៌កំបាំងអ្វីខ្លះនៅពេលនោះរវាងព្រះករុណានឹងបា
រាំង ឬដោយព្រះករុណាខ្លាចដូចព្រះនរោត្តម-សុធារស ដែលបារាំងឈប់ឲ្យសោយ
រាជ្យ ដោយដឹងថា ព្រះនរោត្តម-សុធារសបើបានឡើងសោយរាជ្យ នឹងទាមទារកម្ពុ
ជាក្រោមពីបារាំង ដូចព្រះចុតហ្មាយដែលព្រះអង្គសរសេរនោះ ។ បើព្រះករុណាខ្លា
ចបារាំងគំរាមកំហែងទម្លាក់ព្រះអង្គចេញពីព្រះរាជបល្ល័ង្ក បើព្រះអង្គនៅតែទទូចទា
មទារកម្ពុជាក្រោម ចុះពេលដែលបារាំងឈប់ធ្វើអាណានិគមលើប្រទេសកម្ពុជា គឺ
ប្រទេសកម្ពុជាបានឯករាជ្យចាប់ពីឆ្នាំ១៩៥៣មក ក៏មិនឃើញពត៌មានថា ព្រះករុណា
ចាប់ផ្តើមទាមទារកម្ពុជាក្រោមពីបារាំង ដែលប្រគល់ឲ្យវៀតណាមមកខ្មែរវិញដែរ ?
ចុះការពិតនៅត្រង់ណា ? បើបារាំងមិនគំរាមកំហែងព្រះករុណាទេ អំពីបញ្ហាកម្ពុជា
ក្រោមនេះ ចុះហេតុដូចម្តេចបានជាព្រះករុណាបញ្ឈប់មិនទាមទារតទៅទៀត មិនតែ
ប៉ុណ្ណោះព្រះអង្គបានឃាត់គណៈប្រតិភូ មិនឲ្យនឹកនារឿងនេះទៀត បានសេចក្តីថា
ការទាមទារកម្ពុជាក្រោមត្រូវបិទបញ្ចប់ត្រឹមនេះ ។ ហេតុដូចម្តេចបានជាត្រូវបិទប-
ញ្ឈប់ចំពោះការបាត់បង់ទឹកដីនិងជនរួមជាតិដ៏ច្រើនរាប់លាននៅលើទឹកដីនោះ ដែ-
លចោរប្លន់យកទៅ ? ព្រះអង្គបានមានព្រះបន្ទូលក្នុងព្រះចុតហ្មាយនោះតទៅទៀត
ថា «អំពីកម្ពុជាក្រោមនេះ ខ្ញុំក៏មានមហិច្ឆិតាចង់បាន ដើម្បីឲ្យកម្ពុជាលូតលាស់ទូលំ
ទូលាយ មិនមែនក្រៀមក្រំ ហើយតូចនោះទេ» ។ ព្រះករុណាចង់បាន ប៉ុន្តែព្រះករុ
ណាមិនទាមទារ តើបានសេចក្តីថាដូចម្តេច ? ឬព្រះអង្គយល់ថា កម្ពុជាក្រោមនឹងវិ
លមកកម្ពុជាវិញ ដោយមិនចាំបាច់ប្រឹងប្រែងទាមទារ ? ឬក៏ព្រះអង្គសុខព្រះទ័យឲ្យ
កម្ពុជាក្រោមបាត់បង់ទៅចុះ ឲ្យតែព្រះករុណាស្ថិតនៅលើព្រះរាជបល្ល័ង្ក កុំឲ្យមានទំ
នាស់នឹងបារាំង ? គឺកម្ពុជាក្រោមប្តូរគ្នានឹងរាជបល្ល័ង្ក ? ព្រោះពេលនោះអំណាច
គ្រប់យ៉ាងស្ថិតនៅលើព្រះករុណា ។ ការស្នេហាជាតិស្នេហាទឹកដី ពុំមែនស្ថិតនៅ
លើព្រះឱស គ្រាន់តែពោលនោះទេ តែត្រូវស្ថិតនៅលើសកម្មភាពធ្វើឲ្យគេឃើញ ។
ព្រះអង្គមានព្រះបន្ទូលថា «ចំពោះកម្ពុជាក្រោមក្តី បន្ទាត់ប្រេវីយេក្តី ខ្ញុំមិនដែលបាន

និយាយថា ខ្ញុំសុខចិត្តប្រគល់ទៅឲ្យបារាំង ថៃ ប្រទេសវៀតណាមដែលខ្លាំងជាងយើង កុំឲ្យមកលេបត្របាក់ពង្រួញទំហំទឹកដីខ្មែរយើងតទៅទៀតបាន ។ ហេតុដូច្នេះហើយបានជាខ្ញុំសុំឲ្យប្រទេសនានាទទួលស្គាល់ជាផ្លូវការ នូវព្រំដែនកម្ពុជានាបច្ចុប្បន្នកាល ។ ខ្ញុំសូមបញ្ជាក់ថា នេះមិនមែនមានន័យថា សុខចិត្តផ្ទេរកម្ពុជាក្រោម កោះត្រល់ ទៅឲ្យបារាំងនិងវៀតណាមនោះទេ» ។ ក្រៅពីចុតហ្មាយនេះ ជនជាតិខ្មែរធ្លាប់ឮព្រះករុណាមានព្រះបន្ទូលតាមវិទ្យុជាតិសម័យសង្គមរាស្ត្រនិយមថា បងប្អូនកូនចៅកុំគិតពីកម្ពុជាក្រោម ត្រូវនាំគ្នាគិតពីបូរណភាពទឹកដីក្នុងព្រំដែនខ្មែរបច្ចុប្បន្ន កុំឲ្យគេរំកិលមកទៀត ។ កាលពីឆ្នាំ១៩៩០ សមាគមខ្មែរកម្ពុជាក្រោមបានទៅធ្វើសវនាការជាមួយព្រះករុណា ជាមួយសំណើថា សូមព្រះករុណាអនុញ្ញាតឲ្យសិស្សនិស្សិតខ្មែររៀនក្នុងសាលា អំពីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ។ នៅពេលនោះ ព្រះករុណាមានព្រះបន្ទូលបែបរារាំងពុំចង់ឲ្យលើកយកមកសិក្សាជាប្រវត្តិសាស្ត្រ។ នេះជាឯកសារមើលតាមវីដេអូ ។ កម្ពុជាក្រោមក្តី កោះត្រល់ក្តី បើព្រះករុណាពុំធ្វើការតវ៉ាទាមទារឈ្មោះថាព្រះករុណាប្រគល់ឲ្យវៀតណាមទាំងស្រុង ហើយទទួលស្គាល់ថា ជារបស់វៀតណាមថែមទៀត ព្រោះអ្វី ? ព្រោះថា តាមច្បាប់បើបិទបញ្ជីឈប់តវ៉ាឈ្មោះថា នេះបង់កម្មសិទ្ធិរបស់ខ្លួនទៅឲ្យអ្នកដទៃហើយ ។ តាមពិត ពេលនោះរហូតមកទល់ពេលនេះគ្មានច្បាប់ណាហាមឃាត់មិនឲ្យខ្មែរតវ៉ាទាមទារអំពីទឹកដីដែលបានបាត់បង់ទៅដូចជាដីកម្ពុជាក្រោម, កោះត្រល់ជាដើម ប៉ុន្តែខ្មែរខ្លួនឯងសុខចិត្តចុះចាញ់មុនប្រយុទ្ធ ។ បើព្រះករុណាខំប្រឹងប្រែងទាមទារតាំងពីឆ្នាំ១៩៤៩ មកទារហើយទារទៀតរៀងរាល់ឆ្នាំ រហូតមកដល់ឆ្នាំ២០០៧នេះ ចំនួនជាង៦០ឆ្នាំ កម្ពុជាក្រោមអាចក្លាយជាបែបណាមួយ ឬអាចបានមកជាកម្មសិទ្ធិរបស់ខ្មែរវិញផងក៏មិនដឹង ។ បានឬមិនបានឲ្យតែមានការតស៊ូ គេមិនបន្ទោសទេ ប៉ុន្តែមិនបានដោយគ្មានការទាមទារនោះជាកំហុស គេត្រូវតែបន្ទោសចំពោះអ្នកទទួលខុសត្រូវ ។ ពាក្យថា ខ្ញុំស្រឡាញ់កម្ពុជាក្រោម ប៉ុន្តែមិនបានទាមទារ ឈ្មោះថាស្រឡាញ់តែមាត់ អួតអាងតែមាត់ គ្មានបានធ្វើអ្វី ព្រោះសេចក្តីសំរេចគ្រប់យ៉ាងកើតមកពីការងារល្អការងារត្រឹមត្រូវ ពុំមែនកើតមកពីមនោរថ គឺពីចិត្តនឹកគិតឡើយ នេះជាពុទ្ធភាសិត ។ ការវិភាគមកនេះ ពុំមែនចោទព្រះករុណាថា មិនស្នេហាជាតិស្នេហាទឹកដីនោះទេ ប៉ុន្តែលើកយកមកពិគ្រោះនេះដើម្បីចង់ដឹងហេតុផលខាងដើមនៃការបាត់បង់កម្ពុជាក្រោមនេះ ដែលមានការពាក់ព័ន្ធមកលើព្រះអង្គនៅពេលនោះ ហើយបានជាពន្លឺប្រវត្តិសាស្ត្រ ក្នុងការត្រួសត្រាយផ្លូវសំរាប់ជនរួមជាតិខ្មែរកម្ពុជាក្រោមដ៏អភ័ព្វ ដែលកំពុងតស៊ូដើម្បីសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង ។ បើព្រះករុណាសព្វព្រះទ័យបំភ្លឺថែមទៀត សូមមេត្តាបំភ្លឺថា ហេតុអ្វីបានជាព្រះអង្គបិទសំណុំរឿងកម្ពុជាក្រោមនេះ មិនព្រមតវ៉ាទាមទារឲ្យបានខ្លាំងក្លាតទៅទៀត ? ចំពោះបារាំងកំហូច ដែលហ៊ានយកទឹកដីខ្មែរទៅប្រគល់ឲ្យយួន ព្រះករុណាបានបញ្ជាក់ហើយថា «បារាំងចង់ជួយបាវដាយឲ្យ

មានកេរ្តិ៍ឈ្មោះចំពោះប្រជាជាតិវៀតណាម ដើម្បីកុំឲ្យហូ-ជីមិញច្បាំងនឹងបារាំង ឈ្នះ បារាំងក៏ផ្ទេរកម្ពុជាក្រោមថ្វាយព្រះចៅបាដាយទៅ» ។ ទីបំផុត សូមថ្វាយព្រះពរសព្វសារធុការ សូមព្រះករុណាមានព្រះជន្មឃឺនយូរ ព្រះសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ដើម្បីបំភ្លឺដល់ជនរួមជាតិខ្មែរកម្ពុជាក្រោម ដែលកំពុងតស៊ូរើបំរះពីអាណានិគមនិយមវៀតណាម ។៚

❁ ❁

❁